ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * *

ក្រសួងសុខាភិបាល
លេខ: ៥៧៦ អ.ប.ស/ឱ.អ.ប.ស

រាជធានីភ្នំពេញ,ថ្ងៃទី ៦ ខែ ១០ ឆ្នាំ ១៩៩៨

# ប្រកាស

## ស្ដីពី

## បែបបទ និង លក្ខខ័ណ្ឌ ក្នុងការសុំបើក ឬបិទ ឬប្ដូរទីតាំង នៃអគារលក់ឱសថបុរាណ

* * *

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញ ច្បាប់ ស្ដីពី ការបង្កើតក្រសួងសុខាភិបាល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤_០១_៩៦

បានឃើញ ច្បាប់ ស្ដីពី ការគ្រប់គ្រងឱសថ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧_មិថុនា_១៩៩៦

បានឃើញ អនុក្រឹត្យលេខ ២៣ អនក្របក ចុះថ្ងៃទី ២៨_មេសា_១៩៩៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពី ផលិតកម្ម អាហរ័ណ និហរ័ណកម្ម និងពាណិជ្ជកម្មឱសថបុរាណ សំរាប់វិស័យសុខាភិបាល ។

យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សំរេច

*ប្រការ១* : ការបើក ការបិទ និង ការប្ដូរទីតាំង នៃអគារលក់ឱសថបុរាណ អាចប្រព្រឹត្តទៅបានលុះត្រាតែបាន ទទួលការអនុញ្ញាត ពីក្រសួងសុខាភិបាល ។

*ប្រការ២* : អាចមានសិទ្ធិសុំបើក អគារលក់ឱសថបុរាណបាន គ្រូថ្នាំបុរាណទាំងពីរភេទ ដែលមានលក្ខណៈ សម្បត្តិដូចខាងក្រោម :

- មានសញ្ញាតិខ្មែរ
- មានការយល់ដឹងក្នុងការផ្សំឱសថបុរាណពីរុក្ខជាតិ សត្វ ឬសិលាជាតិ និងការពិនិត្យព្យាបាល ជម្ងឺសាមញ្ញតាមវេជ្ជសាស្ត្របុរាណ ដែលមានវិញ្ញាបនប័ត្រគ្រូថ្នាំបុរាណទទួលស្គាល់ ដោយ ក្រសួងសុខាភិបាល
- មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ
- មានសុខភាពគ្រប់គ្រាន់អាចបំរើការងារបាន ។

ទីស្ដីការស្ដីការក្រសួងសុខាភិបាល លេខ ១៥១_១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរសារ_ទូរស័ព្ទ : (៨៥៥_២៣) ២៦៨៤១_៦៦២០២
MINISTRY OF HEALTH N° 151-153 AVENUE KAMPUCHEA KROM PHNOM PENH CAMBODIA. FAX-PHONE (855-23) 26841 - 66202

ប្រការ៣ : សំណុំលិខិតសុំបើក អគារលក់ឱសថបូរាណមាន :

១_ពាក្យសុំបើក "មានគំរូ"

២_វិញ្ញាបនប័ត្រគ្រូថ្នាំបូរាណ ទទួលស្គាល់ដោយក្រសួងសុខាភិបាល

៣_ប្រវត្តិការងារសង្ខេបរបស់សាម៉ីជន "មានគំរូ"

៤_វិញ្ញាបនប័ត្រសុខភាពចេញដោយមន្ទីរពេទ្យរដ្ឋណាមួយ

៥_លិខិតថ្កោលទោសដែលមានរយៈពេលមិនលើសពី ៣ខែ

៦_គំនូសបំព្រួញទីតាំង ដោយមានចំណារឯកភាពពីអាជ្ញាធរដែនដី និងរូបថតបង្ហាញទីតាំង

៧_រូបថតសាម៉ីជន ៤ x ៦ សម. ចំនួន៥សន្លឹក

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល "នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង" ក្រោយពីបានទទួលយោបល់ពីមន្ទីរសុខាភិបាលរាជធានី_ខេត្ត ក្រុង ។

ប្រការ៤ : ក្រសួងសុខាភិបាល នឹងផ្តល់ចម្លើយ អំពីការសុំបើក ឬការសុំប្តូរទីតាំងអគារលក់ឱសថបូរាណ ដល់សាម៉ីជនយ៉ាងយឺតបំផុត ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសំណុំលិខិតគ្រប់គ្រាន់និងត្រឹមត្រូវ នៅនាយកដ្ឋានឱសថ_ចំណីអាហារ_បរិក្ខារពេទ្យនិងគ្រឿងសំអាង ។

ប្រការ៥ : គ្រូថ្នាំបូរាណមួយរូប មានសិទ្ធិដាក់ពាក្យសុំបើកអគារលក់ឱសថបូរាណបានតែមួយកន្លែង និងមិនអាចប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតឡើយ។

ប្រការ៦ : ការសុំប្តូរទីតាំងនៃអគារលក់ឱសថបូរាណ ត្រូវបំពេញសំណុំលិខិតដូចខាងក្រោម :

១_ពាក្យសុំប្តូរទីតាំង "មានគំរូ"

២_លិខិតអនុញ្ញាបើក" ច្បាប់ដើម"

៣_គំនូសបំព្រួញទីតាំងថ្មី ដោយមានចំណារឯកភាពពីអាជ្ញាធរដែនដី និងរូបថតបង្ហាញទីតាំងថ្មី

៤_រូបថតរបស់សាម៉ីជន ៤ x ៦ ស.ម ចំនួន ៥សន្លឹក

សាម៉ីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកនាយកដ្ឋានឱសថ ចំណីអាហារ_បរិក្ខារពេទ្យនិងគ្រឿងសំអាង ក្រោយពីបានទទួលយោបល់ពីមន្ទីរសុខាភិបាលរាជធានី_ខេត្តក្រុង ។

ប្រការ៧ : ការសុំផ្លាស់ប្តូរគ្រូថ្នាំបូរាណដែលទទួលខុសត្រូវអគារលក់ឱសបូរាណ ត្រូវបំពេញសំណុំលិខិតដូចខាងក្រោម

១_ពាក្យសុំផ្លាស់ប្តូរ "មានគំរូ"

២_កិច្ចព្រមព្រៀងផ្លាស់ប្តូរ" មានគំរូ"

៣_លិខិតអនុញ្ញាតបើក" ច្បាប់ដើម"

៤_វិញ្ញាតបនប័ត្រគ្រូថ្នាំបូរាណ របស់គ្រូថ្នាំបូរាណជំនួស

៥_ប្រវត្តិការងារសង្ខេបរបស់អ្នកជំនួស "មានគំរូ"

៦_លិខិតថ្កោលទោស ដែលមានរយៈពេលមិនលើសពី ៣ខែរបស់អ្នកជំនួស

៧_រូបថត ៤ x ៦ ស.ម ចំនួន ៥សន្លឹក របស់អ្នកជំនួស

៨-វិញ្ញាបនប័ត្រសុខភាព ចេញដោយមន្ទីរពេទ្យណាមួយរបស់អ្នកជំនួស ។

សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកក្រសួងសុខាភិបាល "នាយកដ្ឋានឱសថ-ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង" ក្រោយពីបានទទួលយោបល់ពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត ក្រុង ។

*ប្រការ៨* : អំពីការរៀបចំអគារលក់ឱសថបូរាណ :

អគារលក់ឱសថបូរាណ ត្រូវដាច់ចេញពីការស្នាក់នៅ មានអនាម័យស្អាតបាត ទាំងខាងក្នុង ទាំងខាងក្រៅ និងមានការរៀបចំសមស្របតាមការកំណត់ដូចខាងក្រោម :

១-មានផ្ទៃក្រឡាអាជីវកម្មយ៉ាងតិច ១៦ ម៉ែ

២-មានផ្លាកសញ្ញា អគារលក់ឱសថបូរាណ " ត្រឹមត្រូវ"

៣-មានទូរ និង កំណាល់គ្រប់គ្រាន់សំរាប់តាំងឱសថ

៤-មានឃ្លាំងស្តុកឱសថបូរាណត្រឹមត្រូវ

៥-បន្ទប់ផ្សំឱសថប្រសិនបើមាន ត្រូវរៀបចំអោយបានសមស្របតាមបច្ចេកទេសឱសថសាស្ត្រ ។

*ប្រការ៩* : អគារលក់ឱសថបូរាណអាចតាំងលក់នូវប្រភេទថ្នាំបូរាណដូចខាងក្រោម :

១-រុក្ខជាតិ សត្វ ឬ សិលាជាតិគ្រប់ប្រភេទ ដែលមិនទាន់កែច្នៃឬបានកែច្នៃតាមវិធីសាស្ត្រ សាមញ្ញ ដែលមានគុណភាពបង្ការ ឬព្យាបាលជម្ងឺ លើកលែងតែរុក្ខជាតិពុល ដែលមានក្នុង បញ្ជីហាមឃាត់របស់ក្រសួងសុខាភិបាល ។

២-ផលិតផលឱសថបូរាណ ដែលមានលេខទិដ្ឋាការ ឬ បញ្ជិការរួចហើយពីក្រសួងសុខាភិបាល។

*ប្រការ១០* : អគារលក់ឱសថបូរាណមានសិទ្ធិដូចតទៅ :

១-លក់រាយនូវផលិតផលដូចមានចែងក្នុងប្រការ ៩

២-ផ្សំឱសថបូរាណមួយចំនួនតាមក្បួនវេជ្ជសាស្ត្របូរាណដោយមានការអនុញ្ញាតពីក្រសួង សុខាភិបាល ។

៣-ពិនិត្យព្យាបាលជម្ងឺ ដោយប្រើឱសថបូរាណ ។

*ប្រការ១១* : ត្រូវហាមឃាត់ ÷

១-ការលក់ឱសថបូរាណក្លែងក្លាយ គ្មានគុណភាព ។

២-ការលក់ឱសថបូរាណដែលផ្សំលាយជាមួយឱសថសម័យ ។

៣-ការលក់ឱសថបូរាណដែលបង្កគ្រោះថ្នាក់ មានក្នុងបញ្ជីហាមឃាត់របស់ក្រសួងសុខាភិបាល ។

៤-ការប្រកបអាជីវកម្មផ្សេងទៀតក្នុងអគារលក់ឱសថបូរាណ ។

៥-ការផ្សព្វផ្សាយពាណិជ្ជកម្មឱសថបូរាណដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

៦-ការព្យាបាលជម្ងឺដោយប្រើឱសថសម័យ ឬវេជ្ជសាស្ត្រសម័យ ។

*ប្រការ១២* : ក្នុងអគារលក់ឱសថបូរាណ ត្រូវមានវត្តមានរបស់គ្រូថ្នាំបូរាណ ដើម្បីគ្រប់គ្រងសកម្មភាពពាណិជ្ជកម្មឱសថបូរាណ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។ ក្នុងករណីអវត្តមានគ្រូថ្នាំបូរាណទទួលខុសត្រូវ ត្រូវមានគ្រូថ្នាំបូរាណមួយរូបទៀតជំនួស ដោយមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ១៣ : ក្រសួងសុខាភិបាលនឹង ដកហូតវិញនូវច្បាប់អនុញ្ញាតបើក ឬប្តូរទីតាំង ឬប្តូរគ្រូថ្នាំឬភាណទទួលខុសត្រូវនៃអគារលក់ឱសថបូរាណ ក្នុងករណីពិនិត្យឃើញថា :

១_សំណុំលិខិតមានលក្ខណៈក្លែងបន្លំ

២_ឬ សាមីជនអនុវត្តមិនត្រឹមត្រូវតាមប្រការ ៨_៩_១០_១១_១២

៣_ឬ សាមីជនជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ ។

ដោយមិនទាន់គិតពីទោសបញ្ញត្តិដែលបានចែងនៅក្នុងច្បាប់ឱសថ ។

ប្រការ១៤ : ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងមន្ទីរសុខាភិបាលរាជធានី ខេត្ត_ក្រុង មានភារកិច្ច ត្រួតពិនិត្យ ការអនុវត្តតាមប្រការនេះអោយមានប្រសិទ្ធិភាព តាមភារកិច្ចរៀងខ្លួន ។

ប្រការ១៥ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៦ : ប្រកាសនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
- គ្រប់មន្ទីរសុខាភិបាល ខេត្ត_ក្រុង
- ព្រះរាជកិច្ច ( ទីស្តីការគណៈរដ្ឋមន្ត្រី )
- ឯកសារ
- កាលប្បវត្តិ

វេជ្ជ.ឈា.ថាង